# ទិវាកុមារ ១ មិថុនា ២០១៣
# បានបង្កើនការយកចិត្តដាក់ បង្កលក្ខណៈឲ្យជួបគ្នា
# និងសម្តែងភាពសប្បាយរីករាយរបស់កុមារគ្មានឱកាស



កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៣ វេលាម៉ោងប្រាំបី និងសាមសិបនាទីព្រឹកនៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តតាកែវបានប្រារព្ធខួបលើកទី៦៤ទិវាកុមារអន្តរជាតិ១មិថុនា និងខួបលើកទី១២ទិវាពិភពលោកប្រឆាំងនិងពលកម្មកុមារអន្តរជាតិ ១មិថុនា ។ លោក សោម អ៊ុំមុន្នីរ៉ា ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិ សម្បទា និង ជាអនុប្រធានក្រុមប្រឹក្សាជាតិដើម្បីកុមារប្រចាំខេត្តតាកែវ(កជក) បានធ្វើសេចក្តីរាយការណ៍និងស្វាគមន៍ជូនលោក ឈិត សុខុន អភិបាលរងខេត្តតាកែវ និងជាប្រធានគណអធិបតី ពីស្ថានភាពទូទៅរបស់កុមារមកពីមណ្ឌលកុមារកំព្រានិងកុមារគ្មានឪកាសមកពីសហគមន៏ក្នុងខេត្តតាកែវដែលមានកុមារចូលរួមសរុបចំនួន ៣៣០នាក់/ស្រី១៤៨នាក់ ក្នុងនោះ អង្គការ ភីសុីបាននាំកុមារកំព្រា និងកុមារងាយរងគ្រោះដោយសារមេរោគអេដស៏និងដោយសារប្រការផ្សេងៗចូលរួមក្នុងពិធីនេះដែរមានចំនួន៤២នាក់។

យោងតាមសារលិខិតរបស់រាជរដ្ឋាភិបាលបានលើកឡើងថា ដើម្បីជាឧត្តមប្រយោជន៏របស់កុមារ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិកុមារនៅថ្ងៃ១៥ ខែតុលា ឆ្នាំ១៩៩២ ហើយរដ្ឋធម្មនុញ្ញនៃព្រះរាជណាចក្រកម្ពុជាឆ្នាំ១៩៩៣បានចែងថា រដ្ឋធានារក្សាសិទ្ធិរបស់កុមារ ដែលមានចែកក្នុងអនុសញ្ញាស្តីអំពីសិទ្ធិកុមារនេះ។ ដើម្បីចូលរួមចំណែកឆ្លើយតបទៅនឹងសារលិខតនេះ និងជួយដល់កុមារឱ្យមានសិទ្ធិពេញលេញ អង្គការភីសុីបានចូលរួមចំណែកប្រារព្ធពិធីនេះឡើងក្នុងគោលបំណងគឺ៖ ចង់ឲ្យប្រជាជនទាំងអស់នៅក្នុងប្រទេសកម្ពុជា ជាពិសេសប្រជាជននៅក្នុងខេត្តតាកែវនេះ បានយកចិត្តទុកដាក់លើកុមារនិងលើកកំពស់ពីតម្លៃរបស់កុមារ ហើយចូលរួមប្រឆាំងនឹងពលកម្មកុមារធ្ងន់ធ្ងរ, បញ្ឈប់ពលកម្មកុមារបម្រើតាមផ្ទះ, ការជួញដូរកុមារ ពេស្យាចារលើកុមារ ហើយបែរមកលើស្នួយកុមារ ដោយអភិវឌ្ឍន៏កុមារឲ្យក្លាយជាគ្រឹះមួយសម្រាប់អភិវឌ្ឍន៏ជាតិ ចាត់ទុកកុមារជាទំពាំងស្នងឬស្សី កុមារជាអនាគតរបស់ជាតិ និងអប់រំកុមារឲ្យក្លាយជាកុមារបីល្អគឺ៖ កូនល្អ សិស្សល្អ មិត្តល្អ និងអនាគតជាប្រជាពលរដ្ឋល្អ។



នៅក្នុងកម្មវិធីនេះដែរ ក្រុមសិល្បៈកុមារបានសម្តែងពីរឿងទាក់ទងទៅនឹងការជួញដូរពលកម្មលើកុមារ

អំពើហឹង្សា និងបញ្ហាគ្រឿងញៀន។



បន្ទាប់មកតំណាងកុមារបានឡើងអានចាប់អារម្មណ៍បង្ហាញពីភាពរំភើបផង និងភាពលំបាកផង និងភាពងាយរងគ្រោះរបស់កុមារនៅក្នុងសង្គមសព្វថ្ងៃថា៖ កុមារមិនសូវមានភាពកក់ក្ដៅពីគ្រួសារនិងសង្គមទេ។ កុមាររស់នៅក្នុងគ្រួសារមួយចំនួនធំកំពុងមានស្ថានភាពលំបាកនិងអំពើហឹង្សា មានការរំលោភបំពាន ការកេងប្រវ័ញ្ចលើកម្លាំងពលកម្ម ខ្វះខាតជីវភាពរស់នៅ និងធ្វើការយ៉ាងធ្ងន់ធ្ងរទៀតផង។ ទន្ទឹមនឹងនេះ កុមារក៏បានបង្ហាញពីការរំភើបរំជួលចិត្តយ៉ាងខ្លាំង ដោយមើលឃើញពីការយកចិត្តទុកដាក់របស់រដ្ឋ និងអង្គការបានធ្វើឱ្យពួកគេមានសេចក្ដីសង្ឃឹម និងមានឱកាសបានសិក្សាដូចកុមារដែលរស់ក្នុងគ្រួសារមានជីវភាពល្អជាងខ្លួន។ ពួកគេបានប្ដេជ្ញាចិត្តខិតខំរៀនសូត្រឲ្យបានល្អប្រសើរដើម្បីអនាគតរបស់ខ្លួន។

តាមសំដីរបស់កុមារី ធី ធារ៉ា អាយុ ៧ឆ្នាំ ជាកុមារកំព្រាឪពុក រស់នៅជាមួយម្ដាយមេម៉ាយដែលមានមុខរបរជាអ្នកស៊ីឈ្នួលលាងចាន បានចូលរួមក្នុងពិធីទិវា១មិថុនាឲ្យដឹងថា៖ នាងខ្ញុំមានចិត្តសប្បាយរីករាយណាស់បានចូលរួមក្នុងពិធីនេះ បានជិះឡានជាលើកដំបូង បានញ៉ាំអាហារឆ្ងាញ់ៗ។

គ្រួសាររបស់ធារ៉ា ជាគ្រួសារមួយក្រីក្របំផុត គ្មានដីគ្មានផ្ទះ មានអំពើហឹង្សា ជីវភាពរស់នៅលំបាក បងៗរបស់នាង២នាក់ទៀតបានឈប់រៀនអស់ហើយ ជួយរកស៊ីម្ដាយ ដើម្បីចិញ្ចឹមជីវិតប្រចាំថ្ងៃតែប៉ុណ្ណោះ ចំណែកធារ៉ាកំពុងរៀនថ្នាក់ទី១នៅសាលាមួយនៅក្នុងភូមិថ្កុល់ទក្សិណ ឃុំក្រាំងធ្នង់ ក្រោមការជួយគាំទ្ររបស់អង្គការភីស៊ី*(តាមសំដីរបស់លោក សុខ ឡាសាធជាបុគ្គលិកគាំទ្រកុមារ)*។




*រូបភាពកុមារកំព្រា និងកុមារងាយរងគ្រោះនិងអ្នកស្ម័គ្រចិត្ត*